រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

024KH01A-01

ការហាត់រៀនធ្វើជាគ្រូគង្វាល



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

២៤

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

របៀបចាប់ផ្តើមក្រុមជំនុំដំបូងបង្អស់



កំណត់ចំណាំ

© Project WorldReach © SEAN

ពេលដែលអ្នកចាប់ផ្តើម ដំបូងបំផុត អ្នកត្រូវអធិស្ឋានទូលសូមឱ្យ ព្រះជាម្ចាស់ជួយដឹកនាំ ។ បន្ទាប់មក សូមអានម៉ាថាយ ២៨:១៦-២០ ដោយហ្មត់ចត់ ហើយឆ្លើយសំណួរទាំងនេះ (គ្រូ បង្ហាត់របស់អ្នកនឹងពិនិត្យមើលអត្ថបទសិក្សានេះជាមួយអ្នក នៅ ពេលជួបគ្នាម្តងទៀត) ។

១- តើអ្នកណាដែលបង្គាប់ឱ្យ« ចេញទៅ » (គឺថាធ្វើសកម្មភាព) និងបង្កើតសាវ័កនៅគ្រប់ជាតិសាសន៍ ?

_____

២- តើព្រះយេស៊ូមានអំណាចអ្វីខ្លះ សំរាប់ចេញសេចក្តីបង្គាប់ដូច នេះ ?

_____

៣- សេចក្តីបង្គាប់នេះ ព្រះជាម្ចាស់ប្រទានមកតាំងពីយូរឆ្នាំមក ហើយ ។ ប៉ុន្តែ សព្វថៃនេះ ក៏ជាសេចក្តីបង្គាប់សំរាប់អ្នក ផ្ទាល់ដែរ ។ កម្មវិធី « បង្ហាត់បង្រៀន និង បង្កើនចំនួន បន្ត »ជាកម្មវិធីសំរាប់ជួយអ្នកឱ្យអាចប្រតិបត្តិតាមសេចក្តី បង្គាប់នេះប្រកបដោយប្រសិទ្ធិភាព ។ ដូចនេះហើយ បង ប្អូនគ្រីស្តជន យើងខ្ញុំសូមអញ្ជើញអ្នក ដូចតទៅ...

កំណត់ចំណាំ

๔- ដើម្បីអាចយល់កិច្ចការ ដែលយើងត្រូវធ្វើ នៅពេលដែលយើង**ចេញទៅ** សូមសិក្សាខ ១៩ និង ខ២០ ដែលបង្ហាញអំពីអ្វីៗដែលព្រះយេស៊ូបង្គាប់អោយយើងធ្វើ ។



ព្រះយេស៊ូបង្គាប់អោយយើងបង្កើតសាវ័ក ហើយព្រះយេស៊ូមានព្រះបន្ទូលប្រាប់យើងអំពីរបៀបបង្កើតសាវ័កដែរ ។ តើព្រះយេស៊ូមានព្រះបន្ទូលប្រាប់យើងអោយធ្វើកិច្ចការពីរយ៉ាងអ្វីខ្លះ ដើម្បីបង្កើតសាវ័ក ?

ក្រៅពីធ្វើពិធីជ្រមុជអោយអ្នកជឿ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ យើងត្រូវបង្រៀនគេឱ្យចេះប្រតិបត្តិតាមដែរ ។ តើអ្នកដែលចង់ធ្វើជាសាវ័ករបស់ព្រះអង្គនោះ ត្រូវប្រតិបត្តិតាមអ្វី ?

កំណត់ចំណាំ

© Project WorldReach © SEAN

- ស្ម័គ្រចិត្តរួមរងទុក្ខលំបាកដើម្បីព្រះគ្រីស្ត ដោយគ្មានមហិច្ឆិតារកផលប្រយោជន៍ផ្ទាល់ខ្លួន (២ ធីម៉ូថេ ២: ២-៤) ។
- ធ្វើតាមពាក្យទូន្មានរបស់គ្រូបង្ហាត់កិច្ចការឃ្វាលរបស់ខ្ញុំ ហើយបំពេញគ្រប់កិច្ចការឃ្វាល និងកិច្ចការសិក្សាដោយស្មោះត្រង់ ។

ឈ្មោះ _____

កាលបរិច្ឆេទ _____

កំណត់ចំណាំ

_____

_____

_____

_____

_____

_____

_____

យើងត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលព្រះយេស៊ូបានបង្គាប់ ។ តើយើងត្រូវបង្កើតសាវ័កបែបនេះ នៅឯណា ?

_____

យើងជាក្រុមជំនុំ ត្រូវបង្កើតសាវ័កគ្រប់ជាតិសាសន៍ (គឺគ្រប់កុលសម្ពន្ធ សហគមន៍ និងវប្បធម៌) ។

៥- នៅក្នុងកម្មវិធី « បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត » យើងបង្កើតសាវ័ក ដូចដែលព្រះយេស៊ូបង្គាប់អោយយើងធ្វើ ។ តើអ្នកយល់ស្របនឹងកិច្ចការនេះ ឬទេ ? _____

៦- យើងអនុវត្តកិច្ចការនេះ ដោយធ្វើពិ _____ អោយអស់អ្នកដែលកែប្រែចិត្តគំនិត និងទទួលព្រះយេស៊ូគ្រីស្ត ជាព្រះសង្គ្រោះ និង ព្រះអម្ចាស់របស់គេ ព្រមទាំងប_____ គេអោយប្រតិបត្តិ _____ សេចក្តីទាំងប៉ុន្មានដែលព្រះយេស៊ូបានបង្គាប់ ។

© Project WorldReach © SEAN

៧- ខ ១៩ ប្រាប់យើងថាត្រូវបង្កើតសាវ័កនៅ « គ្រប់ជាតិសាសន៍ » ។ ទីកន្លែងបង្កើតសាវ័កធំណាស់ ! ប៉ុន្តែ កិច្ចការ ១:៨ ពន្យល់ពីរបៀបធ្វើសកម្មភាព ដើម្បីអនុវត្តសេចក្តីបង្គាប់នេះ ។ សូមសរសេរឈ្មោះតំបន់ដែលបង្ហាញពីការពង្រីកការផ្សាយដំណឹងល្អ :

យ _____(ស្រុកកំណើត)

យូ _____(តំបន់ជុំវិញ)

សា _____(ប្រទេសជិតខាង)

រហូតដល់ _____(ប្រទេសឆ្ងាយ)

- ដាក់ដង្វាយជាប្រាក់ និងជាពេលវេលាសំរាប់ការពង្រីកព្រះរាជ្យរបស់ព្រះអង្គ នៅគ្រប់កន្លែងដែលព្រះអង្គត្រាស់ហៅខ្ញុំអោយទៅ (ម៉ាថាយ ២៨:១៨-២០) ។
- ទុកចិត្តថា ឫទ្ធានុភាពរបស់ព្រះអង្គ អាចធ្វើអោយក្រុមជំនុំរីកចំរើន និងបង្កើនចំនួនបន្ត (ម៉ាកុស ៤) ។
- ខិតខំប្រកាន់យកតម្រូវការសំរាប់ពួកអ្នកដឹកនាំរបស់ក្រុមជំនុំអោយបានខ្ជាប់ខ្ជួន ដូចដែលមានចែងក្នុង ១ ធីម៉ូថេ ៣:១-៧ ។
- ពន្យល់ដំណឹងល្អដោយស្ងាហាប់ ដោយទឹកចិត្តស្រឡាញ់ និងច្បាស់លាស់ ដើម្បីអោយមនុស្សជឿ និងប្រតិបត្តិតាមព្រះជាម្ចាស់ (ម៉ាថាយ ២៨:១៩-២០) ។
- ខិតខំបង្កើតក្រុមជំនុំថ្មីៗ ដែលនឹងបង្កើតក្រុមជំនុំសាខាបន្ត ជាពិសេស នៅក្នុងតំបន់ដែលមិនទាន់មានក្រុមជំនុំនៅឡើយ (រ៉ូម ១៥:២០-២១) ។

ពាក្យសន្យារបស់និស្សិតនៃកម្មវិធី
"បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត"

ដោយមានព្រះជាម្ចាស់ជួយ ខ្ញុំសូមសន្យាថានឹង :

- ស្រឡាញ់ព្រះអង្គ និងប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលព្រះអង្គបានបង្គាប់ អោយបានមុនអ្វីៗទាំងអស់ (សំរាប់ខ្លួនខ្ញុំផ្ទាល់ និងពួកអ្នកដែលខ្ញុំបង្រៀន) ។

- ថែរក្សាគ្រួសារខ្ញុំ ដោយទឹកចិត្តស្រឡាញ់ស្មោះ (អេភេសូ ៥) ។

- អធិស្ឋានជាប់ជាប្រចាំ ដើម្បីអោយមានជោគជ័យក្នុងការងារបំរើព្រះជាម្ចាស់ (អេភេសូ ៦:១៨) ។

- ធ្វើការងារយ៉ាងខ្លាំងជាមួយអ្នកដទៃ ដោយសេចក្តីស្រឡាញ់ និងដោយមានការស្រុះស្រួលគ្នា ជាពិសេសជាមួយក្រុមជំនុំរបស់ខ្ញុំ ដោយផ្តល់ពតិមានអំពីសកម្មភាពរបស់ខ្ញុំប្រាប់ពួកគេជានិច្ច (រ៉ូម ១២:៩-១១) ។

៨- ពួកសាវ័កស្តាប់តាមសេចក្តីបង្គាប់នោះ ហើយក្រុមជំនុំក៏ចាប់ផ្តើមរីកចំរើន ។ គឺសាវ័កប៉ូលដែលត្រូវក្លាយជាជើងឯកខ្លាំងបំផុត ខាងការពង្រីកក្រុមជំនុំរបស់ព្រះគ្រីស្ត ទៅក្នុងចំណោមជាតិសាសន៍ ដែលមិនមែនជាជាតិសាសន៍យូដា ។ ឥឡូវនេះ យើងនឹងមើលពីរបៀបដែលគាត់ធ្វើ ។



៩- ឥឡូវនេះ សូមអាន ២ ធីម៉ូថេ ២:១-១០ ។ លោកប៉ូលមិនត្រឹមតែផ្សាយដំណឹងល្អ ដើម្បីបង្កើតក្រុមជំនុំថ្មីប៉ុណ្ណោះទេ គាត់ថែមទាំងបានបង្កើតបណ្តាញគ្រូបង្ហាត់ និងអ្នកបំរើនៅពេញក្នុងចក្រភព្រ៉ូម៉ាំង ដោយធ្វើតាមសេចក្តីដែលគាត់និយាយនៅក្នុង ខ ២ ។

"សេចក្តីទាំងអស់ដែលអ្នកបានឮពីខ្ញុំ នៅមុខសាក្សីជាច្រើននាក់ ត្រូវប្រគល់អោយបងប្អូនណាដែលស្មោះត្រង់ និងមានសមត្ថភាព អាចបង្រៀនបន្តទៅអ្នកផ្សេងទៀតចុះ" ។

ប៉ូល
(កាំទីមួយ)

សិស្សរបស់ប៉ូល
ដូចជាធីម៉ូថេ និង ទីតុស
(កាំទីពីរ)

មនុស្សដែលស្មោះត្រង់
និងមានសមត្ថភាព
(កាំទីបី)

មនុស្សឯទៀត
(កាំទីបួន)



នៅទីបញ្ចប់ សូមអានពាក្យសន្យារបស់កម្មវិធី "បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត" ដែលមាននៅទំព័របន្ទាប់ ។ សូមអធិស្ឋាន ហើយពិចារណាពីផ្នែកនិមួយៗ រួចជំរាបឲ្យគ្រូណែនាំរបស់អ្នកដឹង បើសិនជាអ្នកយល់ព្រមតាមពាក្យសន្យានេះ ។



គ) អ្នកត្រូវសិក្សាមេរៀនខ្លីៗ តាមដែលអ្នកត្រូវការ ។

_____

ឃ) អ្នកមិនសូវជួបនឹងគ្រូដែលបង្ហាត់បង្រៀនអ្នកទេ ។

_____

ង) កម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត» ត្រូវបានអនុវត្តជាជំហានស្រួលៗ ។ _____

ច) គ្រូបង្ហាត់កិច្ចការឃ្វាលរបស់អ្នក រៀបចំផែនការអោយអ្នក និងបង្គាប់អ្នកថា ត្រូវសិក្សាអ្វីខ្លះ ។ _____

ឆ) នៅពេលដែលអ្នករៀបចំផែនការ គ្រូបង្ហាត់កិច្ចការឃ្វាលរបស់អ្នក នឹងជួយណែនាំអ្នក ក្នុងការរៀបចំផែនការ និងក្នុងការអនុវត្តតាមផែនការទាំងនោះ ។

_____

ចំលើយ :

ក) «ខុស» ខ) «ត្រូវ» គ) «ត្រូវ» ឃ) «ខុស»
ង) «ត្រូវ» ច) «ខុស» ឆ) «ត្រូវ»

១០- អ្នកបំរើម្នាក់ៗបានបង្រៀនពីសេចក្តី ដែលគាត់បានរៀនប្រាប់ទៅក្រុមជំនុំរបស់ខ្លួន និងប្រាប់អ្នកបំរើឯទៀត ។ ក្រុមជំនុំ និងអ្នកបំរើទាំងនោះ នឹងបន្តបង្រៀនសេចក្តីទាំងនោះទៅអ្នកផ្សេងៗទៀត ដែលបង្កើតបានជាបណ្តាញមួយគ្មានទីបញ្ចប់ ។ នេះជារបៀបដែលគ្រីស្តជនដំបូងធ្វើដើម្បីនាំប្រទេសខ្លួនមកថ្វាយព្រះគ្រីស្ត ។ សព្វថ្ងៃនេះ ព្រះវិញ្ញាណដ៏វិសុទ្ធជំរុញចិត្តយើងអោយធ្វើដូចនេះដែរ ។ នេះជាកិត្តិយស និងការទទួលខុសត្រូវដ៏ធំ ។

១១- នេះជាគោលការណ៍ច្បាស់លាស់ដែលជាមូលដ្ឋានរបស់កម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត» :

«ក្រុមជំនុំដែលស្តាប់បង្គាប់ និងមានសុខភាពល្អ
ប្រៀបដូចជាដើមឈើដែលលូតលាស់ឡើង
និងបន្តពូជគ្មានទីបញ្ចប់» ។



ដើម្បីអោយអាចយល់គោលការណ៍ជាមូលដ្ឋាននៃកម្មវិធី « បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត »បាន សូមអានរឿងពិតអំពីរបៀបដែលកម្មវិធីនេះចាប់ផ្តើម ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើព្រះយេស៊ូបង្គាប់អោយសិស្សរបស់ព្រះអង្គធ្វើអ្វី មុនពេលដែលព្រះអង្គយាងត្រឡប់ទៅព្រះបិតាព្រះអង្គវិញ ?

_____

_____

សំរាប់ពួកសាវ័ក ការស្តាប់បង្គាប់តែងតែចាប់ផ្តើម ដោយការធ្វើពិធីជ្រមុជទឹក បន្ទាប់មក បង្រៀនពួកអ្នកថ្វាយខ្លួនអោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងប៉ុន្មានទៀតរបស់ព្រះគ្រីស្ត ។

២- សូមសរសេរថា « ត្រូវ » ឬ « ខុស » នៅក្រោយឃ្លាដែលរៀបរាប់យ៉ាងពិតប្រាកដពីកម្មវិធី « បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត » ខាងក្រោមនេះ ។

ក) អ្នកត្រូវទៅរៀននៅសាលាព្រះគម្ពីរច្រើនឆ្នាំ ។ _____

ខ) អ្នកត្រូវសិក្សា និងធ្វើកិច្ចការឃ្វាលក្នុងស្ថានភាពរបស់ជីវិតអ្នកផ្ទាល់ ។ _____

© Project WorldReach © SEAN

បើអាចធ្វើបាន អ្នកគួរសិក្សា :

☐ នៅកន្លែងស្ងាត់ ដែលគ្មានការរំខាន ។

☐ នៅកន្លែងភ្លឺល្អ និងមានខ្យល់ល្អ ។

បើអាចធ្វើបាន អ្នកគួរដាក់គ្រឿងសង្ហារឹម (តុ ទូ កៅអី) សំខាន់ៗ ខាងក្រោមនេះ :

☐ តុមួយ ឬ តុការិយាល័យមួយ និងកៅអីមួយ ។

☐ ទូដាក់សៀវភៅមួយ សំរាប់ដាក់សម្ភារៈគ្រប់យ៉ាងរបស់អ្នក អោយនៅមូលគ្នា ។

☐ ក្តារខៀនមួយសំរាប់កត់សកម្មភាពរបស់អ្នក ។

បើតាមស្ថានភាពរបស់អ្នក តើអ្នកនឹងសិក្សានៅឯណា ?



របៀបចាប់ផ្តើមកម្មវិធី "បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត" ដំបូងបង្អស់

កាលពីច្រើនឆ្នាំមុន គ្រូបង្រៀនសាលាព្រះគម្ពីរម្នាក់អស់សង្ឃឹមជាខ្លាំង ។



ព្រះជាម្ចាស់មានបន្ទូលប្រាប់លោកគ្រូនោះ តាមរយៈព្រះគម្ពីរព្រះ-អង្គ អំពីអ្នកដែលគាត់ត្រូវបង្ហាត់បង្រៀនជាគ្រូគង្វាល និងអំពីរបៀបដែលគាត់ត្រូវធ្វើ ។



មិនយកចិត្តទុកដាក់នឹងគ្រួសារខ្លួន ដោយគិតថាត្រូវតែថ្វាយខ្លួនដាច់ទៅព្រះជាម្ចាស់ ។ តើ ១ ធីម៉ូថេ ៣:៤-៥ ចែងដូចម្តេចអំពីការនេះ ?

_____

_____

- ក្រៅពីត្រូវសិក្សាតាមពេលកំណត់ បើអាចធ្វើបាន គួរតែសិក្សានៅកន្លែងតែមួយរហូត ។ ធ្វើដូចនេះ អ្នកមានរបស់គ្រប់យ៉ាងនៅក្បែរដៃ ហើយអ្នកស្រួលនឹងផ្ចង់ចិត្តគំនិត ។



© Project WorldReach © SEAN

- កំណត់យកពេលដែលខួរក្បាលអ្នកធូរស្រាលស្រឡះ ធ្វើជាពេលម៉ោងសិក្សា ។ ការសិក្សាពេលយប់ប្រសើរជាងសំរាប់មនុស្សខ្លះ ចំពោះមនុស្សខ្លះទៀត ការសិក្សាពេលព្រឹកជាការល្អ ។
- កំណត់យកពេលដែលមិនសូវមានការរំខាន ធ្វើជាពេលម៉ោងសិក្សា។

តើថ្ងៃណា និងម៉ោងណា ដែលប្រសើរបំផុតសំរាប់បំពេញកិច្ចការឃ្វាល និងការសិក្សារបស់អ្នក ?

_____

_____

_____

កំណត់ចំណាំពិសេស : នៅពេលធ្វើតារាងពេលវេលារបស់អ្នក សូមនឹកចាំពីគ្រួសាររបស់អ្នកផង ។ គ្រូគង្វាលជាច្រើនបានធ្វើអោយកិច្ចការបំរើរបស់ខ្លួនអន្តរាយ ដោយសារ

ប៉ុន្តែ នៅមានបញ្ហាមួយទៀត គឺពួកអ្នកចាស់ទុំមានការទទួលខុសត្រូវច្រើន ដូច្នេះ គេរវល់ណាស់ គ្មានពេលសំរាប់រៀនច្រើនដូចនេះទេ ។ ពួកគេក៏ពិបាកអានសៀវភៅរបស់ខ្ញុំ ដែលរៀបរាប់អំពីព្រះជាម្ចាស់ដែរ ព្រោះសៀវភៅទាំងនោះមានអត្ថន័យជ្រៅៗពេក ។ តើខ្ញុំត្រូវធ្វើដូចម្តេចទៅ ?



នៅពេលដែលគាត់ជិះរទេះភ្លើងទៅភូមិមួយ ដើម្បីជ្រើសរើសចាស់ទុំម្នាក់យកមកបង្រៀន ចិត្តគាត់នៅស្មាក់ស្មើរនៅឡើយ ប៉ុន្តែ ពេលនោះគាត់យល់ថា...



- ត្រូវធ្វើតាមកាលវិភាគរបស់អ្នកសំរាប់ពេលខាងមុខ ដោយម៉ត់ចត់ ដើម្បីកាត់ចោលកិច្ចការគ្រប់យ៉ាងដែលមិនកសាងក្រុមជំនុំជាក់ស្តែង ។ រៀបចំគំរោងរយៈពេលជាប់ៗគ្នា មិនដាច់ សំរាប់ភារកិច្ចសំខាន់ៗបំផុត ។ ត្រូវទុកពេលវេលាគ្រប់គ្រាន់សំរាប់គ្រួសារអ្នក និង សំរាប់សំរាក ។

- វាយតម្លៃកិច្ចការដែលអ្នកធ្វើសព្វថៃនេះ ។ ដោយសារតែក្នុងមួយថៃមាន ២៤ ម៉ោង ទើបអ្នកត្រូវធ្វើផែនការ និងទុកពេលច្រើនសំរាប់ធ្វើ**កិច្ចការឃ្វាល** និង **ការសិក្សា** របស់អ្នក ។ ប្រហែលជាអ្នកត្រូវគិតគួររៀបចំឡើងវិញ ឬក៏ត្រូវលប់ចោលសកម្មភាពខ្លះៗ ដែលអ្នកធ្លាប់ធ្វើ ។

  ឥឡូវនេះ :

  - ធ្វើតារាងពេលវេលាសំរាប់កិច្ចការឃ្វាល និងការសិក្សារបស់អ្នកផ្ទាល់ ។ សូមកុំទុកកិច្ចការទាំងនេះចោលរហូតដល់មានពេលទំនេរឡើយ ។

  - រៀបចំរយៈពេលសិក្សាខ្លីៗច្រើនថ្ងៃ ប្រសើរជាងធ្វើទាំងអស់តែមួយថ្ងៃ ។

- យើងដឹងថា អ្នកពិតជារវល់ណាស់ ប៉ុន្តែ អ្នកដែលប្រកាសថា ខ្លួនមានពេលតិចណាស់ ច្រើនតែធ្វើអ្វីៗមិនបានជោគជ័យ ។ តាមធម្មតា បញ្ហាមិនមែនស្ថិតត្រង់ថា គ្មានពេលនោះទេ តែគឺស្ថិតនៅលើរបៀបរៀបចំពេលវេលាទៅវិញទេ ។

- គ្រូគង្វាលឈ្លាសវៃប្រើប្រាស់ពេលវេលារបស់គាត់ ទៅតាមកាលវិភាគ ដែលគាត់ធ្វើ ។ យើងមិនមែនសុំអោយអ្នកធ្វើកាលវិភាគ បែងចែកពេលវេលាគ្រប់នាទីជាមុននោះទេ ព្រោះអាចកំរិតសេរីភាពរបស់អ្នក ក្នុងការធ្វើតាមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។ ប៉ុន្តែ អ្នកត្រូវរៀបចំធ្វើគំរោងពេលវេលា សំរាប់ធ្វើកិច្ចការសំខាន់ៗ ។

- បើអ្នកធ្វើដូចនេះ នោះមានប្រយោជន៍ដល់អ្នកណាស់ គឺសូមធ្វើបញ្ជីមួយពីកិច្ចការគ្រប់យ៉ាង ដែលអ្នកបានធ្វើហើយនៅក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយ ដែលអ្នកអាចនឹកចាំបាន ។ បន្ទាប់មក សំរេចថាកិច្ចការណាជាកិច្ចការសំរាប់ការងារព្រះជាម្ចាស់ និងកិច្ចការណាមិនមែន រួចអធិស្ឋានទូលសូមអោយចេះប្រើប្រាស់ពេលវេលារបស់អ្នក ដើម្បីអាចយកចិត្តទុកដាក់ចំពោះសកម្មភាពដែលសំខាន់ៗបំផុត ។



ប៉ុន្មានអាទិត្យក្រោយមក ជនសរសើរតម្កើងព្រះជាម្ចាស់...



តើនឹងមានបញ្ហាអ្វីកើតឡើង បើសិនជាអ្នកដើរទៅអធិប្បាយ នៅក្នុងកន្លែង ដែលមានអ្នកផ្សេងទទួលខុសត្រូវហើយ ដោយមិនសុំអនុញ្ញាតិពីអ្នកនោះ ?

ការទទួលខុសត្រូវរបស់អ្នកក្នុងឋានៈជានិស្សិត :



អ្នកណាអួសទាញអ្នកណា ?

(សូមគូស «✓» នេះ នៅត្រង់ចំលើយដែលត្រឹមត្រូវ)

ដូចគ្នានេះដែរ ក្នុងឋានៈជានិស្សិតគ្រូគង្វាល អ្នកត្រូវធ្វើកិច្ចការ :

☐ តាមតែចិត្តអ្នក ។

☐ ដោយសមប្រកបជាមួយក្រុមជំនុំរបស់អ្នក ។

អ្នកបំពេញកិច្ចការឃ្វាលម្នាក់ ដែលត្រូវក្រុមជំនុំបញ្ជូនអោយទៅកន្លែងផ្សេង ត្រូវត្រឡប់មកក្រុមជំនុំដើមរបស់ខ្លួនវិញ ដើម្បីរាយការណ៍អំពីការរីកចំរើននៃការងាររបស់ខ្លួន (កិច្ចការ ១៤:២៥-២៨) ។ ហេតុអ្វីបានជាក្រុមជំនុំរបស់អ្នក ត្រូវតែដឹងពីកិច្ចការដែលអ្នកធ្វើ ?



លោកគ្រូចាប់ផ្តើមកត់ត្រាពីសេចក្តីដែលព្រះយេស៊ូបានបង្គាប់.....





អ្នកក៏ត្រូវធ្វើការងារស្មុះស្មួលជាមួយសមាជិកឯទៀត ក្នុងឋានៈជារូបកាយរបស់ព្រះគ្រីស្តដែរ ។ ព្រះជាម្ចាស់មិនចង់អោយអ្នកមានស្មារតីឯករាជ្យ មិនគោរពតួកអ្នកដឹកនាំដែលត្រឹមត្រូវរបស់ក្រុមជំនុំនោះទេ ។ យោងទៅតាម កិច្ចការ ១៣:១-៣ ព្រះ-ជាម្ចាស់មានបន្ទូលមកកាន់កូនៗព្រះអង្គ តាមរយៈព្រះបន្ទូលរបស់ព្រះអង្គ និង :

- ☐ មតិរបស់មនុស្សយើង ។
- ☐ ក្រុមជំនុំរបស់អ្នក ។

ក្នុងឋានៈជាអ្នកចំពេញកិច្ចការឃ្វាល អ្នក :

មិនត្រូវចំណូលស្រា ។



មិនត្រូវឈ្លោះប្រកែក តែត្រូវមានចិត្តសប្បុរស ។



មិនមែនជាអ្នកស្រឡាញ់ប្រាក់ ។



មិនមែនជាអ្នក ដែលទើបនឹងជឿ ។



ក្រោយមក...



ប៉ុន្មានអាទិត្យក្រោយមក...



ចេះបង្រៀន ។



(បើរៀបការហើយ)

ត្រូវមានភរិយាតែមួយប៉ុណ្ណោះ ហើយចេះមើលខុសត្រូវលើក្រុមគ្រួសាររបស់គាត់ផ្ទាល់ (ព្រោះថា ប្រសិនបើមនុស្សម្នាក់មិនចេះមើលខុសត្រូវលើក្រុមគ្រួសាររបស់ខ្លួនផង ធ្វើម្តេចនឹងអោយគាត់មើលខុសត្រូវលើក្រុមជំនុំរបស់ព្រះជា-ម្ចាស់កើត !) ។





ក្នុងបាន:ជាអ្នកបំពេញកិច្ចការឃ្វាល អ្នកត្រូវ :



មានគុណសម្បត្តិល្អឥតខ្ចោះ និងមានកេរ្តឹ៍ឈ្មោះល្អពីសំណាក់អស់អ្នកដែលមិនមែនជាគ្រីស្តបរិស័ទផងដែរ ។



ចេះទទួលភ្ញៀវ ។



មានចិត្តធ្ងន់ មិនចេះរករឿងនិងមានកិរិយាមារយាទល្អ។



ឥឡូវនេះ សូមឈានមួយជំហានដោយជំនឿ គឺអធិស្ឋាន ហើយសរសេរឈ្មោះមនុស្ស និងទីកន្លែងដែលអ្នកអាច**ចេញទៅបង្កើតសាវ័ក** ដោយមានព្រះជាម្ចាស់ជួយ ។

ក្រៅពីភារៈកិច្ចដែលអ្នកត្រូវបំពេញក្នុងការងារឃ្វាល អ្នកក៏ត្រូវបង្កើនលក្ខណៈសម្បត្តិផ្ទាល់ខ្លួនដែរ ដើម្បីអាចបំពេញមុខងារបំរើប្រកបដោយប្រសិទ្ធិភាព ដូចដែលមានបង្ហាញជូននៅទំព័របន្តបន្ទាប់ទៅនេះ (១ ធីម៉ូថេ ៣:១-៧) ។

អ្នកឯទៀត ។ នៅក្នុងម៉ាថាយ ២៨ ព្រះយេស៊ូមានបន្ទូលប្រាប់អោយយើងបង្កើតសាវ័ក ។ សេចក្តីបង្គាប់អោយបង្កើតសាវ័កនេះនាំអោយបំពេញមុខងារបំរើជាច្រើន ដូចជា ផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត បង្រៀនសាវ័កថ្មីឱ្យចេះស្តាប់បង្គាប់ ឃ្វាលហ្វូងចៀម រិះគិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ចាត់គ្រីស្តទូតឱ្យចេញទៅ និងបង្រៀនគ្រីស្តជន ព្រមទាំងអប់រំគ្រីស្តជនគ្រប់ផ្នែក ។

តើសព្វថ្ងៃនេះ អ្នកបំរើព្រះជាម្ចាស់នៅឯណា ?

_____

តើសព្វថ្ងៃនេះ អ្នកធ្វើអ្វីដើម្បីប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត ?

_____

_____

_____

_____

ក្នុងរយៈពេលម្តែឆ្នាំ ក្រុមជំនុំថ្មីចំនួនជាងមួយរយបានរីកចំរើន និងបង្កើនចំនួនបន្ត ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ និងពង្រីកព្រះរាជ្យរបស់ព្រះអង្គ ។



គោលការណ៍នៃព្រះគម្ពីរទាំងនេះ ដែលគេបានអនុវត្តនៅជនបទហុងឡ្គ៉ារ៉ាស់ ត្រូវបានគេយកទៅអនុវត្តប្រកបដោយប្រសិទ្ធិភាពជាបន្តបន្ទាប់ នៅតាមទីក្រុងតូចធំ តាមភូមិស្រុក និងតំបន់ជនបទពាសពេញពិភពលោកទាំងមូល ។

តើអ្នកមានបំណងចង់ចូលរួមក្នុងកម្មវិធីបង្ហាត់បង្រៀនគ្រួគង្វាលដូចនេះ ដែរឬទេ ? បើមាន សូមអានបន្ត ។

តើកម្មវិធី "បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត" ជាអ្វី ?

១- ដំបូង គឺជាកម្មវិធីដែលតម្រង់កិច្ចការដែលត្រូវអនុវត្តសំរាប់ពួកអ្នកដែលត្រូវបំពេញ**កិច្ចការឃ្វាល** ។ ក្នុងឋានៈជានិស្សិតរបស់កម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត» អ្នកត្រូវផ្សព្វផ្សាយដំណឹងល្អ និងបង្រៀនអ្នកឯទៀតអោយក្លាយទៅជាសាវ័កផងដែរ ។

ពួកអ្នកដែលគ្រាន់តែចង់ចេះព្រះគម្ពីរ តែមិនអនុវត្តតាមសេចក្តីបង្រៀនរបស់ព្រះគម្ពីរ មិនអាចជ្រើសយកជានិស្សិតទេ ។

២- ទីពីរ គឺជា**ការសិក្សា** ។ អ្នកនឹងសិក្សា**អត្ថបទព្រះគម្ពីរ**ហើយនិងអនុវត្តតាមព្រះបន្ទូលនោះ ដោយប្រើ**កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល** ដែលគេបានរៀបចំជាពិសេស ដើម្បីជួយអ្នក ។

សូមរកមើលនៅក្នុង លូកា ២២:១៩-២០ អំពីកិច្ចការដែលអ្នកត្រូវធ្វើជាទៀងទាត់ ក្នុងឋានៈជារូបកាយរបស់ក្រុមជំនុំ ដើម្បីសរសើរតម្កើងព្រះគ្រីស្ត :

_____

_____

យើង «កាច់នំបុ័ង» ដើម្បីធ្វើពិធីជប់លៀងព្រះអម្ចាស់ ដោយសារយើងស្តាប់បង្គាប់ព្រះយេស៊ូ ។ មុខងារបំរើខាងថ្វាយបង្គំ រីកចំរើនដោយសារសេចក្តីបង្គាប់នេះ ។

សូមអាន ម៉ាថាយ ៤:៤ ។ តើ «អាហារ» ណា ដែលយើងត្រូវទទួលទានរាល់ថ្ងៃ ?

_____

_____

សាវ័កទាំងអស់របស់ព្រះគ្រីស្ត អានព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាអាហារខាងព្រលឹងវិញ្ញាណ ព្រមទាំងបង្រៀនព្រះបន្ទូលដល់

យើងត្រូវអោយដោយសេចក្តីស្រឡាញ់ ។ អ្នកត្រូវបង្រៀនសាវ័ករបស់អ្នក អោយចេះអោយដោយចិត្តសប្បុរស ។ មុខងារខាងការគ្រប់គ្រងថវិកា រីកចំរើនដោយសារសេចក្តីបង្គាប់នេះ ។

សូមអានម៉ាថាយ ២២:៣៧-៤០ ។ តើសេចក្តីបង្គាប់ណាមួយដែលសំខាន់ជាងគេបំផុត ? សេចក្តីបង្គាប់នោះ មានពីរផ្នែក ។ សូមសរសេរផ្នែកទាំងពីរជាពាក្យពេចន៍អ្នកផ្ទាល់ :

_____

_____

_____

សាវ័កស្មោះត្រង់ទាំងអស់ សុទ្ធតែស្រឡាញ់ព្រះជាម្ចាស់អស់ពីចិត្ត និងស្រឡាញ់បងប្អូនឯទៀត ដូចស្រឡាញ់ខ្លួនឯង ។ មុខងារបំរើទាំងអស់ រីកចំរើនដោយសារសេចក្តីបង្គាប់ទាំងនេះ រួមទាំងមុខងារបំរើខាងមេត្តាករុណា ដែលនាំអោយយើងបំរើមនុស្សដែលខ្វះខាតផងដែរ ។ ព្រះយេស៊ូមានបន្ទូលនៅក្នុង យ៉ូហាន ១៤:១៥ ថា÷ *«ប្រសិនបើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ អ្នករាល់គ្នាពិតជាកាន់តាមវិន័យរបស់ខ្ញុំ »* ។

៣- ទីបី **គ្រូបង្ហាត់កិច្ចការឃ្វាល**របស់អ្នក នឹងជីកនាំអ្នកគ្រប់ពេល ទាំងពេលបំពេញកិច្ចការឃ្វាល ទាំងពេលសិក្សា ។

៤- ដូច្នេះ កម្មវិធី « បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត » មានបីផ្នែក ដូចតទៅនេះ :

កិច្ចការឃ្វាលដែលអ្នកត្រូវធ្វើក្នុងស្ថានភាពពិតនៃជីវិតអ្នកផ្ទាល់ ។

ការសិក្សានៅផ្ទះ ដោយប្រើមេរៀនស្រួលអនុវត្ត និងស្រួលយល់ ។

ការជួបជុំជាទៀងទាត់ជាមួយគ្រូបង្ហាត់កិច្ចការឃ្វាលរបស់អ្នក ។



ផ្នែកទាំងបីនេះផ្សារភ្ជាប់គ្នាដូចផ្លូវរទេះភ្លើង ។ កិច្ចការឃ្វាល និងការសិក្សារបស់អ្នកជាខ្សែដែក ត្រូវបានផ្សារភ្ជាប់គ្នា ដោយសារការជួបជុំជាទៀងទាត់ជាមួយគ្រូបង្ហាត់កិច្ចការ ឃ្វាលរបស់អ្នក ដើម្បីអោយមានឱកាសចែកចាយ និងធ្វើ គម្រោងអំពីកិច្ចការ ដែលអ្នកត្រូវធ្វើបន្តទៀត ។



យើងបញ្ជាក់ថា គេកែប្រែចិត្តគំនិត ដោយធ្វើពិធីជ្រមុជទឹកអោយ គេ ។ មុខងារបំរើខាងបង្កើតសាវ័ក រីកចំរើនដោយសារការស្តាប់ បង្គាប់ដំបូងនេះ ។

អានម៉ាថាយ ៦:៥-១៣ និង ៧:៧-៨ ។ តើរាល់ថ្ងៃ យើងត្រូវ ធ្វើអ្វីទៀត ?

យើងអធិស្ឋានរាល់ថ្ងៃ ។ ការអធិស្ឋានទូលអង្វរ ដើម្បីអ្នកដទៃ ការអធិស្ឋានសំរាប់អ្នកឈឺ ការអធិស្ឋានជាមួយក្រុមគ្រួសារ ការអធិស្ឋានផ្ទាល់ខ្លួន ការអធិស្ឋានទូលសូមជំយជំនះក្នុងការ ធ្វើសង្គ្រាមខាងព្រលឹងវិញ្ញាណ រីកចំរើនដោយសារសេចក្តី បង្គាប់នេះ ។

សូមអាន ម៉ាថាយ ៦:១៩-២១ ។ តើសាវ័កស្មោះត្រង់របស់ ព្រះគ្រីស្តត្រូវធ្វើអ្វីទៀត ?

តើនៅក្នុងម៉ាកុស ១:១៥ ព្រះយេស៊ូបង្គាប់អោយយើងធ្វើអ្វី ដើម្បីអោយបានសង្គ្រោះ ?

ដើម្បីអោយបានសង្គ្រោះ យើងត្រូវកែប្រែចិត្តគំនិត និងជឿ ។ នៅក្នុងបទព្រះគម្ពីរផ្សេងទៀត យើងឃើញថា យើងក៏ត្រូវទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែរ (យ៉ូហាន ៣:៣-៥, យ៉ូហាន ២០:២២)។ មុខងារបំរើខាងផ្សព្វផ្សាយដំណឹងល្អរីកចំរើន ដោយសារសេចក្តីបង្គាប់នេះ ។

អានម៉ាថាយ ២៨:១៩-២០ និង កិច្ចការ ២:៣៨ ។ តើយើងបញ្ជាក់ថា អ្នកដែលថ្វាយខ្លួនមានជំនឿ និងកែប្រែចិត្តគំនិតដោយរបៀបណា ?

នៅក្នុងកម្មវិធី "បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត" :

- អ្នកត្រូវសិក្សានៅផ្ទះ តាមកិរិត និងសមត្ថភាពរបស់អ្នក ដោយមិនបាច់លះបង់ការងារ និងលះបង់ក្រុមជំនុំរបស់ខ្លួនឡើយ ។

- កម្មវិធីនេះ មិនមែនអោយរូបអ្នកសិក្សាអត្ថបទច្រើនទេ តែកម្មវិធីនេះត្រូវបែងចែកជាជំហានស្រួលៗ ។ សំរាប់ជំហាននិមួយៗ គ្រូបង្ហាត់របស់អ្នកនឹងជូនអ្នកនូវកូនសៀវភៅខ្លីៗ ស្រួលយល់ ម្តងមួយ នៅពេលត្រូវការ ។

- « សៀវភៅណែនាំសកម្មភាពនិស្សិតគ្រូគង្វាល » ដែលគ្រូបង្ហាត់របស់អ្នករក្សាទុកអោយអ្នក មានកម្មវិធីទាំងមូល និង ជូនការសិក្សាសំរាប់ជួយអ្នកឱ្យអាចបំពេញកិច្ចការឃ្វាលរបស់អ្នកបាន ។

- នៅពេលដែលអ្នកចូលសិក្សា អ្នកនឹងជួបប្រជុំជាទៀងទាត់ជាមួយគ្រូបង្ហាត់កិច្ចការឃ្វាលរបស់អ្នក ដើម្បីអធិស្ឋាន ធ្វើការសិក្សា និងរៀបចំកិច្ចការឃ្វាល ដែលអ្នកត្រូវធ្វើនៅពេលខាងមុខ ។

ការហាត់រៀនធ្វើជាគ្រូគង្វាល



ការទទួលខុសត្រូវរបស់អ្នក ក្នុងកិច្ចការឃ្វាល

ក្នុងឋានៈជានិស្សិតគ្រូគង្វាលនៅក្នុងកម្មវិធី «បង្ហាត់បង្រៀន និងបង្កើនចំនួនបន្ត» អ្នកទទួលសេចក្តីបង្គាប់ពីព្រះយេស៊ូផ្ទាល់ ។ អ្នកនឹងសាងសង់មុខងារបំរើទាំងមូលរបស់អ្នកលើគ្រឹះ ដែលជាការស្តាប់បង្គាប់ព្រះគ្រីស្ត និង ពួកសាវ័ករបស់ព្រះអង្គ ។

យើងនិយាយនេះមិនមែនបានន័យថា កិច្ចការដែលអ្នកត្រូវធ្វើគឺគ្រាន់តែបង្រៀនសេចក្តីបង្គាប់ទាំងឡាយរបស់ព្រះយេស៊ូប៉ុណ្ណោះទេ ។ យើងចាប់ផ្តើម ដោយទុកសេចក្តីបង្គាប់ទាំងឡាយរបស់ព្រះជាម្ចាស់ ជាគ្រឹះ ។ បន្ទាប់មក ទើបកសាងសេចក្តីបង្រៀន និងមុខងារបំរើបន្តទៀតទាំងអស់លើ «ថ្ម ដា »ដែលជាគ្រឹះនេះ ។ យើងនឹងមើលឡើងវិញ អំពីសេចក្តីបង្គាប់សំខាន់ៗរបស់ព្រះ-យេស៊ូ ។ ព្រះអង្គប្រទានសេចក្តីបង្គាប់ចំនួនជាងហាសិប ប៉ុន្តែសេចក្តីបង្គាប់ទាំងនោះ សង្ខេបមកជាសេចក្តីបង្គាប់សំខាន់ៗចំនួនប្រាំពីរ ។ នៅក្នុងកិច្ចការ ២:៣៧-៤៧ យើងឃើញមនុស្ស ៣០០០នាក់ថ្វាយខ្លួន ជាសមាជិកក្រុមជំនុំដំបូងនៃសម្ពន្ធមេត្រីថ្មី ដោយប្រតិបត្តិតាមសេចក្តីបង្គាប់ទាំងប្រាំពីរនេះ យ៉ាងត្រឹមត្រូវបំផុត ។